# ព័ត៌មានថ្មីបំផុតអំពីការសិក្សាពីមន្ត្រីជាន់ខ្ពស់គ្រប់គ្រងវិជ្ជាស្ថានអប់រំនៃយើង

1 ឧសភា 2020

ជូនចំពោះប្រជាសហគមន៍ OUSD៖

ឧសភាគឺជាខែមួយដ៏រំភើបសម្រាប់សិស្ស និងបុគ្គលិកទាំងឡាយ នៅពេលដែលយើងបញ្ចប់ឆ្នាំសិក្សា អបអរសាទរសមិទ្ធិផលរបស់យើង និងរង់ចាំពេលឈប់សម្រាកនារដូវក្តៅ។ ឆ្នាំនេះមិនធម្មតាទេ ដូច្នេះនាងខ្ញុំចង់ផ្តល់ជូនបន្តពីអ៊ីមែលមុនរបស់នាងខ្ញុំ ដោយមានការកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះបុគ្គលិកដែលបានខិតខំធ្វើការអស់រយៈពេលជាច្រើនខែកន្លងមកនេះ ក៏ដូចជាព័ត៌មានបន្ថែមមួយចំនួនទៀត។ សូមមើលនៅខាងក្រោមនេះ សម្រាប់ព័ត៌មានថ្មីៗ ធនធាន និងផែនការ ព្រមទាំងគំនិតរបស់យើងនាងខ្ញុំ សម្រាប់បន្តដំណើរទៅមុខទៀត ទាក់ទងនឹងប្រធានបទដូចតទៅនេះ៖ **កម្មវិធីសិក្សាពីចម្ងាយ; បច្ចេកវិទ្យា និងការដោះស្រាយការបែងចែកឌីជីថល (ការបែងចែករវាងអ្នកមាន និងពុំមានកំព្យូទ័រ និងអ៊ិនធឺណិតប្រើប្រាស់នៅឯផ្ទះ); ការដាក់ពិន្ទុ, ប័ណ្ណរាយការណ៍ និងការឡើងថ្នាក់ / ការបញ្ចប់ការសិក្សា; ការសិក្សានាពេលរដូវក្តៅ និងឆ្នាំសិក្សា 2020-21**។

## ការកោតសរសើរ

ថ្ងៃនេះគឺជាថ្ងៃដឹងគុណនាយកសាលា ហើយជាថ្ងៃទី 1 នៃ**ខែដឹងគុណគ្រូបង្រៀនថ្នាក់ជាតិ** នៅពេលដែលយើងឆ្លៀតឱកាសឈប់សម្រាក់បន្តិចសិន និងថ្លែងអំណរគុណដល់នាយកសាលា និងអ្នកអប់រំរបស់យើង ចំពោះការលះបង់ និងការខិតខំរបស់ពួកគេពេញមួយឆ្នាំ។ តាមពិតខែឧសភានេះ គឺមានស្ថានភាពខុសប្លែកខ្លាំងណាស់ ហើយទោះបីយើងមិននៅឯសាលារៀនដើម្បីថ្លែងអំណរគុណដល់អ្នកអប់រំរបស់យើងផ្ទាល់ក៏ដោយ ក៏យើងនៅតែអាចឆ្លៀតគ្រប់ឱកាសនៅក្នុងខែនេះ ដើម្បីបង្ហាញការដឹងគុណដល់អ្នកអប់រំរបស់យើងតាមវិធីផ្សេងទៀត។ ក្នុងនាមជាអតីតគ្រូបង្រៀន និងជានាយកសាលារៀននោះ នាងខ្ញុំដឹងថា តើមានកម្លាំងចិត្តប៉ុនណាទៅ នៅពេលដែលទទួលបាននូវ «ពាក្យថ្លែងអំណរគុណ» ចំពោះការខិតខំប្រឹងប្រែង ដែលអ្នកកំពុងធ្វើក្នុងការបម្រើសិស្ស បុគ្គលិក និងប្រជាសហគមន៍។

នៅពេលដែលសាលារៀនរបស់យើងបានបិទមិនឱ្យមានការបង្រៀនដោយផ្ទាល់នោះ ថ្នាក់ដឹកនាំសាលារៀន និងគ្រូបង្រៀនរបស់យើង បានឆ្លើយតបភ្លាមៗទៅនឹងស្ថានភាពពិបាកនៅក្នុងបរិស្ថានថ្មី ក្នុងកម្មវិធីសិក្សាពីចម្ងាយ។ ពួកគេបានបង្កើតផែនការថ្មីទាំងស្រុង សម្រាប់វិធីដែលសិស្សនឹងបន្តរៀនសូត្រ និងគិតអំពីវិធីនានាដើម្បីធ្វើឱ្យសិស្ស និងក្រុមគ្រួសារចូលរួមក្នុងសហគមន៍សាលារៀន។ ពួកគេបានចូលរួមក្នុងសិក្ខាសាលាតាមអ៊ិនធឺណិត ដើម្បីរៀនពីវិធីថ្មីៗក្នុងការតភ្ជាប់, ពួកគេបានបង្ហាញឥទ្ធិពលបច្ចេកវិទ្យារបស់ពួកគេ ដើម្បីប្រើប្រាស់កម្មវិធីថ្មី, ពួកគេបានធ្វើបច្ចុប្បន្នភាពទៅលើផែនការមេរៀន, ពួកគេបានទាក់ទងដោយផ្ទាល់ទៅក្រុមគ្រួសារ ហើយនិងនៅមានរឿងជាច្រើនទៀត។ សូមចំណាយពេលបន្តិច ដើម្បីកោតសរសើរដល់អ្នកអប់រំរបស់យើង តាមរយៈការផ្ញើអ៊ីមែល ប័ណ្ណ ឬការបង្ហោះនៅលើបណ្តាញសង្គមធដោយប្រើហាស់ថែក (hashtag) #thankATeacher និង #ThankAPrincipal។

នៅពេលយើងឈានដល់ប៉ុន្មានសប្តាហ៍ចុងក្រោយនៃឆ្នាំសិក្សានេះ នាងខ្ញុំនៅតែមានមោទនភាពចំពោះរបៀបដែលអ្នកអប់រំ មាតាបិតា អ្នកថែទាំ បុគ្គលិក និងប្រជាសហគមន៍ កំពុងរួបរួមគ្នាជួយដល់កុមារអូកឡិនដ៍ ទាំងផ្នែកអប់រំ និងអារម្មណ៍តាមរយៈពេលវេលាដែលមិនប្រាកដប្រជាទាំងនេះ។

នាងខ្ញុំបាននិយាយពីមុនរួចហើយថា មានតែវិធីតែមួយគត់ដែលយើងអាចឆ្លងផុតការនេះបាន គឺតាមរយៈការរួបរួមគ្នា, ការលើកចំហរចិត្ត និងការគាំទ្រគ្នាទៅវិញទៅមក ហើយនាងខ្ញុំជឿជាក់លើរឿងនេះជាងពេលណាៗទាំងអស់។

សូមថ្លែងអំណរគុណដល់អ្នកអប់រំរបស់យើងទាំងអស់ ដែលបានយកចិត្តទុកដាក់ខ្ពស់ក្នុងកំឡុងពេលនេះ!

## ការសិក្សាពីចម្ងាយ

យើងមាននៅសល់ពីរដំណាក់កាលនៃការសិក្សាពីចម្ងាយ៖

- ដំណាក់កាលទី 1៖ 16 មីនា - 26 មីនា៖ ភ្ជាប់ទំនាក់ទំនងជាមួយសិស្ស ក្រុមគ្រួសារ និងមិត្តរួមការងារ
- ដំណាក់កាលទី 2៖ ថ្ងៃទី 6-10 ខែមេសា៖ ត្រៀមខ្លួនជាស្រេច

- ដំណាក់កាលទី 3៖  ថ្ងៃទី 13-24 ខែមេសា៖  សាកល្បងមើលសិន
- **ដំណាក់កាលទី 4៖  ថ្ងៃទី 27 ខែមេសាដល់ថ្ងៃទី 22 ខែឧសភា៖  កែលម្អ និងធ្វើឱ្យប្រសើរ**
  អ្នកអប់រំ និងបុគ្គលិកគាំទ្រ នឹងបន្តទទួលបាននូវការគាំទ្រក្នុងការរៀបចំផែនការមេរៀន និងឱកាសសិក្សាប្រកបដោយវិជ្ជាជីវៈ។ ពួកគេនឹងបន្តទំនាក់ទំនងជាមួយសិស្ស និងក្រុមគ្រួសារ និងផ្ដល់ឱកាសរៀនសូត្រ។ សម្ភារៈឧបទេសថ្មីនឹងបន្តណែនាំដល់សិស្សរហូតដល់ថ្ងៃទី 22 ខែឧសភា។
- **ដំណាក់កាលទី 5៖  ថ្ងៃទី 26-28 ខែឧសភា៖  ការឆ្លុះបញ្ចាំង**
  ក្នុងអំឡុងពេលសប្ដាហ៍ចុងក្រោយនៃសាលារៀន គ្មានសម្ភារៈឧបទេសថ្មី ដែលនឹងត្រូវបានណែនាំទេ។ គ្រូបង្រៀន និងសិស្សរបស់យើងនឹងផ្ដោតជាសំខាន់លើការឆ្លុះបញ្ចាំងពីការរៀនសូត្ររួមគ្នា និងការបញ្ចប់ការសិក្សានៅឆ្នាំសិក្សានេះ។

យើងខ្ញុំលើកទឹកចិត្តដល់ក្រុមគ្រួសារឱ្យបន្តការគាំទ្រការរៀនសូត្រនៅឯផ្ទះ តាមការដែលពួកគេអាចធ្វើទៅបាន តាមការប្រើអនុសាសន៍របស់គ្រូបង្រៀន ការបន្តផែនការសិក្សារបស់ពួកគេ ឬ ផែនការបន្តការសិក្សានៃសង្កាត់សាលារៀនអូកឡិនដ៍។

## បច្ចេកវិទ្យា និងការដោះស្រាយការបែងចែកឌីជីថល

នៅសង្កាត់សាលារៀនអូកឡិនដ៍ យើងទទួលស្គាល់ពីសារៈសំខាន់នៃការប្រើប្រាស់ទូទៅនៃបច្ចេកវិទ្យា និងអ៊ិនធឺរណិតប៉ុនណាទៅ ចំពោះការអប់រំ។ សិស្សដែលមានកុំព្យូទ័រ និងអ៊ិនធឺណិតប្រើនៅផ្ទះ អាចទទួលបាននូវការអប់រំរបស់ពួកគេបានច្រើនជាងសិស្សដែលគ្មានកំព្យូទ័រ និងអ៊ិនធឺណិតប្រើប្រាស់។ ពាក់កណ្ដាលនៃសិស្សចំនួន 50,000 នាក់នៅក្នុងសាលារៀនគ្រប់គ្រងដោយសង្កាត់ និងសាលាឆាតធើស្គូល ត្រូវបានផ្ដាច់ចេញពីអ៊ិនធឺណិត ឬភ្ជាប់មិនគ្រប់គ្រាន់ទៅនឹងអ៊ិនធឺណិត។ កាលៈទេសៈនាពេលបច្ចុប្បន្ននេះ បានធ្វើឱ្យផលប៉ះពាល់នៃការបែងចែកឌីជីថលមានលក្ខណៈកាន់តែអាក្រក់ទៅៗ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ វាបានបង្កើនការយល់ដឹងរបស់ប្រជាសហគមន៍អំពីការបែងចែកឌីជីថលនេះ។

នៅពេលដែលយើងបានបិទសាលារៀនមិនឱ្យមានការបង្រៀនដោយផ្ទាល់នោះ យើងបានបានផ្លាស់ប្ដូរយ៉ាងលឿន តាមការដែលយើងអាចធ្វើបាន ក្នុងការវាយតម្លៃលើតម្រូវការរបស់សិស្ស ហើយយើងកំពុងចាត់វិធានការដោះស្រាយវា។

សហគមន៍សាលារៀនរបស់យើង បានខិតខំបំពេញតម្រូវការបច្ចេកវិទ្យាភ្លាមៗរបស់សិស្ស ក្នុងរយៈពេលជាច្រើនសប្ដាហ៍កន្លងមកនេះ។

- យើងបានធ្វើការស្ទាបស្ទង់ពីសាលារៀនមួយទៅសាលារៀនមួយ អំពីតម្រូវការរបស់សិស្ស ហើយចាប់តាំងពីពេលនោះមក យើងខ្ញុំបានចែកចាយកំព្យូទ័រយួរដៃ Chromebook ចំនួន 16,000 គ្រឿងជាងហើយចេញពីបញ្ជីសារពើភណ្ឌ Chromebook នៃសាលារបស់យើង។
- ដៃគូរបស់យើង គឺ Tech Exchange ក៏បានចែកចាយកុំព្យូទ័រយួរដៃចំនួន 440 គ្រឿង, ថែបឡេត (tablet) ចំនួន 302 គ្រឿង ហើយកំពុងដំណើរការចែកចាយកន្លែងមានចំណុចក្ដៅ (hotspot) នៃអ៊ិនធឺណេតជិត 600 កន្លែង។

ជាអកុសល នៅតែមានសិស្សជាច្រើននាក់ដែលត្រូវការកំព្យូទ័រយួរដៃ Chromebook ហើយក៏នៅតែមានសិស្ស និងក្រុមគ្រួសារជាច្រើនទៀតដែលខ្វះអ៊ិនធឺណេតប្រើប្រាស់នៅឯផ្ទះ។ ការធានាយ៉ាងណាឱ្យក្រុមគ្រួសារទាំងអស់នៃសង្កាត់សាលារៀនអូកឡិនដ៍ (OUSD) មានយ៉ាងហោចណាស់កំព្យូទ័រយួរដៃ chromebook មួយគ្រឿង និងមានអ៊ិនធឺណិតប្រើប្រាស់នោះ គឺទាមទារយ៉ាងហោចណាស់ឱ្យយើងមានកំព្យូទ័រយួរដៃ Chromebook ចំនួន 1,423 គ្រឿងថែមទៀត និងមានចំណុចក្ដៅអ៊ិនធឺណិតចំនួន 365 កន្លែងថែមទៀតផងដែរ។ ប៉ុន្តែទោះយ៉ាងណាក៏ដោយ យើងដឹងថាតម្រូវការ គឺនៅមានចំនួនច្រើនជាងនេះទៅទៀត ដើម្បីឱ្យយើងអាចបំបាត់ការបែងចែកឌីជីថលទាំងស្រុងតែម្ដងបាន។ យើងខ្ញុំកំពុងធ្វើការជាបន្ទាន់ជាមួយដៃគូសាធារណៈ និងឯកជន ដើម្បីបំពេញតម្រូវការបច្ចេកវិទ្យារបស់យើង។

នៅពេលដែលយើងបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីផ្ដល់បច្ចេកវិទ្យាសម្រាប់ការសិក្សានៅផ្ទះនោះ យើងខ្ញុំក៏ខិតខំពិនិត្យមើលការបែងចែកឌីជីថលតាមរយៈកញ្ចក់សមធម៌ និងផ្ដោតជាសំខាន់លើការផ្ដល់ការគាំទ្រដល់សហគមន៍របស់យើងដែលមានការយកចិត្តទុកដាក់តិចជាងគេ ហើយដែលខ្វះអ៊ិនធឺណិតប្រើប្រាស់។ ប៉ុន្តែទោះបីជានៅមានកិច្ចការជាច្រើនដែលត្រូវធ្វើក៏ដោយ យើងនាងខ្ញុំមានមោទនភាពចំពោះការងារចុះទាក់ទងជួយដល់សហគមន៍របស់យើង៖

- យើងខ្ញុំបានផ្ដល់ជូនក្រុមគ្រួសារចំនួន 1,528 គ្រួ និងសិស្សក្នុងកម្មវិធីកុមារតូច ចំនួន 1,640 នាក់ដែលមានកញ្ចប់ក្រដាស់សិក្សាកំរិតថ្នាក់ ដើម្បីទ្រទ្រង់ការរៀនសូត្ររបស់ពួកគេ សម្រាប់រយៈពេលដែលនៅសល់ទាំងប៉ុន្មាននៃឆ្នាំសិក្សានេះ។
- យើងខ្ញុំបានផ្ញើរធនធានជាវីដេអូខ្លីៗជូនក្រុមគ្រួសារដែលនិយាយភាសានានាក្រៅពីភាសាអង់គ្លេស ដើម្បីពន្យល់ពីវិធីស្វែងរកព័ត៌មានដែលពួកគេត្រូវការ។
- យើងនាងខ្ញុំកំពុងធ្វើការជាមួយដៃគូសហគមន៍ ដើម្បីធានាយ៉ាងណាឱ្យសេវាកម្មបកប្រែភាសា និងអ្នកបកប្រែផ្ទាល់មាត់ គឺអាចរកបានជូនដល់សហគមន៍សាលារៀន។

- យើងខ្ញុំកំពុងចាប់ផ្តើមធ្វើការជាមួយទូរទស្ស KDOL ដើម្បីចាក់ផ្សាយព័ត៌មាន ជូនក្រុមគ្រួសារតាមរយៈបណ្តាញទំនាក់ទំនងសាធារណៈតាមខ្សែកាបប៉ុស្តិ៍លេខ 27។

## ការដាក់ពិន្ទុ, ប័ណ្ណរាយការណ៍ និង ការបញ្ចប់ការសិក្សា/ការឡើងថ្នាក់

- **ការដាក់ពិន្ទុ៖** ចំពោះសិស្សនៅថ្នាក់ទី 6-12 យើងខ្ញុំកំពុងទទួលយកវិធីសាស្ត្រ មានក្រេឌីត និង/ឬ គ្មានក្រេឌីត សម្រាប់ឆមាសចុងក្រោយនេះ។ ចំពោះសិស្សថ្នាក់មត្តេយ្យ និងបឋមសិក្សាវិញ គ្រូបង្រៀននឹងផ្តោតលើផ្នែកផ្តល់យោបល់សម្រាប់ប័ណ្ណរាយការណ៍ចុងក្រោយ និងមិនដាក់ពិន្ទុណាមួយឱ្យទេ។ ព័ត៌មានលំអិត និងការធ្វើបច្ចុប្បន្នភាពបន្ថែម នឹងត្រូវបានដាក់បង្ហោះនៅលើគេហទំព័រ www.ousd.org/covid-19studentlearning។
- **ប័ណ្ណរាយការណ៍៖** នៅចុងខែឧសភា ប័ណ្ណរាយការណ៍ទំនងជានឹងត្រូវបានផ្ញើតាមអ៊ីមែលជូនគ្រួសារដែលមានអ៊ិនធឺណិតប្រើ ហើយនឹងដាក់ផ្ញើតាមប៉ុស្តិ៍សំបុត្រជូនដល់ក្រុមគ្រួសារដែលពុំមានលទ្ធភាពប្រើប្រាស់អ៊ិនធឺណិត។
- **ការបញ្ចប់ការសិក្សា/ការឡើងថ្នាក់៖** យើងនឹងចែករំលែកផែនការរបស់សាលានីមួយៗនៅសប្តាហ៍ក្រោយ ដើម្បីអបអរសាទរសិស្សថ្នាក់ទី 5 និងថ្នាក់ទី 8 របស់យើង ក៏ដូចគ្នាដែរព័ត៌មានលំអិតអំពីពិធីបញ្ចប់ការសិក្សាសំរាប់សិស្សឆ្នាំបញ្ចប់វិទ្យាល័យរបស់យើង។ សូមថ្លែងអំណរគុណដល់អ្នករាល់គ្នាដែលបានចំណាយពេលវេលា ធ្វើការចែករំលែកគំនិតរបស់ពួកគេដើម្បីធ្វើការអបអរសាទរដល់ក្រុមសិស្សដែលរៀនចប់ឆ្នាំ 2020 របស់យើង!
- **ការបញ្ចប់ការសិក្សា, ការធ្វើតេស្ត, ការអនុញ្ញាតចូលរៀនមហាវិទ្យាល័យ៖** តម្រូវការបញ្ចប់ការសិក្សា និងព័ត៌មានអំពីការធ្វើតេស្ត AP និងតម្រូវការចូលរៀនសកលវិទ្យា UC/CSU ត្រូវបានចែករំលែកកាលពីខែមុនរួចហើយ ហើយថាអាចរកបានផងដែរពីគេហទំព័រ www.ousd.org/covid-19studentlearning។

## ការសិក្សានាពេលរដូវក្តៅ

កម្មវិធីសិក្សារដូវក្តៅរបស់យើង ជាធម្មតាបម្រើសិស្សប្រមាណជា 6,000 នាក់ ចាប់ពីថាក់មត្តេយ្យដល់ថ្នាក់ទី 12 ដោយមានការគាំទ្រជាគោលដៅ និងឱកាសបន្តការសិក្សាដែលត្រូវបានបង្រៀនដោយគ្រូបង្រៀន OUSD របស់យើងដែលមានវិញ្ញាបនបត្រ។ យើងខ្ញុំគ្រោងនឹងរក្សាឱកាសសិក្សានាពេលរដូវក្តៅរបស់យើងសម្រាប់ឆ្នាំ 2020 ដោយមានការផ្លាស់ប្តូរឆ្ពោះទៅរកកម្មវិធីសិក្សាពីចម្ងាយ។ សិស្សត្រូវបានណែនាំដោយសាលារបស់ពួកគេ ហើយនឹងទទួលបាននូវអន្តរាគមន៍ដែលផ្តោតលើអក្ខរកម្ម និងគណិតវិទ្យា។ លើសពីនេះទៀត យើងខ្ញុំកំពុងធ្វើជាដៃគូជាមួយទីភ្នាក់ងារសហគមន៍ ដើម្បីផ្តល់ឱកាសចំពាក់ចំប៉ុនក្នុងពេលរសៀល ដើម្បីជួយសិស្សឱ្យសកម្មឡើង និងភ្ជាប់ទំនាក់ទំនងគ្នាជាមួយនឹងមនុស្សពេញវ័យដែលយកចិត្តទុកដាក់លើពួកគេ បើទោះបីត្រូវធ្វើក្នុងទម្រង់សិក្សាពីចម្ងាយក៏ដោយ។ យើងខ្ញុំកំពុងធ្វើការឱ្យមានជម្រើសខ្ចប់ជាក្រដាស់សម្រាប់ក្រុមគ្រួសារដែលមានលទ្ធិភាពប្រើប្រាស់អ៊ិនធឺណឹតបានតិច។ សូមទាក់ទងសាលារៀនរបស់កូនអ្នក ដើម្បីទទួលបាននូវព័ត៌មានថែមទៀត។

កម្មវិធីបង្កើនក្រេឌិត គឺត្រូវបានផ្តល់ជូនដល់សិស្សានុសិស្សថ្នាក់វិទ្យាល័យ ដែលមានតម្រូវការកម្មវិធីបង្កើនក្រេឌីតពីការសិក្សាមុខវិជ្ជាសិក្សាដើម្បីបញ្ចប់ការសិក្សាឱ្យបានទាន់ពេលវេលា។ សូមទាក់ទងអ្នកប្រឹក្សានៅវិទ្យាល័យរបស់កូនអ្នក ដើម្បីទទួលបាននូវព័ត៌មាន និងសិទ្ធិទទួលបានថែមទៀត។

សម្រាប់ព័ត៌មានថែមទៀត ស្តីពីកម្មវិធីសិក្សានាពេលរដូវក្តៅរបស់យើង សូមចូលទៅកាន់គេហទំព័រ www.ousd.org/summerlearning។ កម្មវិធីភាគច្រើន នឹងមានរយៈពេល 4 សប្តាហ៍ ហើយនឹងប្រព្រឹត្តទៅនៅចន្លោះថ្ងៃទី 8 ខែមិថុនាដល់ថ្ងៃទី 2 ខែកក្កដា ឆ្នាំ 2020។

## ឆ្នាំសិក្សា 2020-21

នៅពេលនិយាយអំពីការបើកសាលារបស់យើងឡើងវិញនោះ សុខភាព និងសុខុមាលភាពរបស់សហគមន៍យើង គឺតែងតែមានអាទិភាពជាចម្បង។ នៅពេលនេះតែម្តង ថ្ងៃទី 10 ខែសីហា ឆ្នាំ 2020 គឺជាថ្ងៃខែឆ្នាំចាប់ផ្តើមតាមការរំពឹងទុកសម្រាប់ឆ្នាំសិក្សា 2020-21។ ថ្ងៃខែឆ្នាំនោះមិនទាន់បានផ្លាស់ប្តូរទេ ប៉ុន្តែដូចអ្នកជ្រាបហើយ ថានេះគឺជាស្ថានភាពគ្មានលំនឹងទេ។ ក្នុងពេលនេះ យើងខ្ញុំកំពុងបង្កើតក្រុមនានា ដើម្បីធ្វើការតាមរយៈព័ត៌មានលំអិតនៅក្នុងផែនការសេណារីយ៉ូរបស់យើង ដើម្បីឱ្យនិយោជិក និងអ្នកពាក់ព័ន្ធទាំងឡាយ ចូលជួយបង្កើតផែនការរបស់យើង ឱ្យឆាប់វិលត្រលប់ទៅសាលារៀនវិញប្រកបដោយសុវត្ថិភាព។ នៅពេលដែលក្រសួងអប់រំរដ្ឋកាលីហ្វ័រញ៉ា (CDE) ចេញផ្សាយព័ត៌មានលម្អិតជាក់លាក់ អំពីវិធីវិលត្រឡប់ទៅសាលារៀនប្រកបដោយសុវត្ថិភាពមក យើងខ្ញុំនឹងធ្វើការកែសម្រួលទៅតាមគោលការណ៍ណែនាំទាំងនោះ។ យើងខ្ញុំនឹងខិតខំរក្សាផ្តល់ជូននូវព័ត៌មានថ្មីចំផុតជូនដល់បុគ្គលិក និងសហគមន៍របស់យើង នៅពេលដែលយើងខ្ញុំស្វែងយល់ថែមទៀត។

យើងខ្ញុំកំពុងបន្តគិតតាមរយៈវិធីច្នៃប្រឌិត ដើម្បីគាំទ្រដល់សិស្សរបស់យើងឆ្ពោះទៅមុខ រួមទាំងវិធីនានាដូចខាងក្រោមនេះ៖

- ពង្រីកកម្មវិធីសិក្សានាពេលរដូវក្តៅ។
- អនុវត្តឆ្នាំសិក្សាបន្ត (ESY) ដែលរៀនសូត្រតាមការប្រើកំព្យូទ័រ សម្រាប់សិស្សដែលមានការគាំទ្រនេះ ដែលបានសរសេរដាក់នៅក្នុងផែនការអប់រំជាលក្ខណៈបុគ្គលរបស់ពួកគេ (កម្មវិធី IEP- ការអប់រំពិសេស) ។
- បង្កើតកម្មវិធីសិក្សាឡើងពីកំរិតទាបទៅខ្ពស់ដូចឡើងស្ពាន សម្រាប់ឱ្យគ្រូបង្រៀនដោះស្រាយគម្លាតនៃការរៀនសូត្រ សម្រាប់សិស្សដែលផ្លាស់ប្តូរពី វគ្គសិក្សា/កំរិតថ្នាក់ទាប ឡើងទៅ វគ្គសិក្សា/កំរិតថ្នាក់ខ្ពស់។ កម្មវិធីសិក្សាឡើងពីកំរិតទាបទៅខ្ពស់ដូចឡើងស្ពាន នឹងផ្តល់ឱកាសដល់លោកគ្រូ-អ្នកគ្រូ ដើម្បីពិនិត្យឡើងវិញលើមុខវិជ្ជាក្នុងកំរិតថ្នាក់ និង/ឬ មុខវិជ្ជាមុនៗ មុនពេលចាប់ផ្តើមមុខវិជ្ជាឆ្នាំសិក្សាបន្ទាប់។
- ស៊ើបអង្កេតវិធីនានាក្នុងការផ្លាស់ប្តូរកាលវិភាគប្រចាំថ្ងៃសិក្សា និង/ឬ សប្តាហ៍សិក្សាតាមទម្លាប់ដើម្បីអនុញ្ញាតសំរាប់គម្លាតសង្គម និងវិធានការសុវត្ថិភាពផ្សេងទៀត។ យើងនាងខ្ញុំនឹងបន្តចូលរួមក្នុងគម្រោងពិភាក្សា ជាមួយ CDC ហើយយើងនាងខ្ញុំនឹងពឹងផ្អែកលើការណែនាំទូទាំងរដ្ឋ ទាក់ទងនឹងថិរវេលានៃថ្នាក់រៀន, ចំនួនសិស្សក្នុងថ្នាក់រៀន ។ល។ នេះអាចរួមមានទាំងសប្តាហ៍សិក្សាដែលបានកំណត់ពេលតៗគ្នា, ក្រុមតូចៗនៃសិស្សនៅក្នុងបរិវេណសាលារៀន និងគំរូសិក្សាទល់មុខនឹងមុខផ្ទាល់ និង/ឬ ផ្សំគ្នាជាមួយនឹងគំរូសិក្សាតាមការប្រើកំព្យូទ័រ ។ល។
- ការស្ទង់មតិលើក្រុមគ្រួសារនារដូវក្តៅអំពីទិដ្ឋភាពនៃបទពិសោធន៍ក្នុងការសិក្សាពីចម្ងាយ ការប្រើប្រាស់ឧបករណ៍ និងរបៀបដែលការផ្លាស់ប្តូរដ៏មានសក្តានុពលមកជាថ្ងៃសិក្សា និង/ឬ សប្តាហ៍សិក្សា អាចជះឥទ្ធិពលដល់គ្រួសារ និងសមត្ថភាពរបស់សិស្ស ក្នុងការទទួលបានជោគជ័យក្នុងការសិក្សា។
- ស្វែងរកឱកាសឱ្យសិស្សទទួលបាននូវកម្មវិធីបង្រៀនថែមទៀត នៅក្នុងកន្លែងសិក្សាបន្ទាប់ពីសាលារៀន តាមរយៈការឧបត្ថម្ភគាំទ្រងបន្ថែម ដូចជាការបង្ហាត់បង្រៀននៅពេលយើងចាប់បន្តការសិក្សាឡើងវិញនៅក្នុងសាលារៀនតែម្តង។

សូមអញ្ជើញចូលរួមជាមួយនាងខ្ញុំក្នុងការថ្លែងអំណរគុណដល់អ្នកអប់រំរបស់យើង នៅពេលដែលពួកគេបន្តរៀបចំ និងអនុវត្តឱកាសសិក្សាប្រកបដោយគុណភាពសម្រាប់សិស្សរបស់យើង និងចូលរួមជាមួយសហគមន៍សាលារៀនរបស់យើង។ សូមបន្តផ្តោតជាសំខាន់លើការឈ្នះដែលមានលក្ខណៈតូចៗជារៀងរាល់ថ្ងៃ។ យើងខ្ញុំកាន់តែតែរឹងមាំឡើងនៅពេលដែលយើងសាមគ្គីគ្នាក្នុងនាមអ្នកក្រុងអូកឡិនដ៍!

សូមចែករំលែកគំនិតរបស់អ្នកអំពីខ្លឹមសារនេះ។

ដោយក្តីថ្លែងអំណរអរគុណពីនាងខ្ញុំ,

Sondra Aguilera
មន្ត្រីជាន់ខ្ពស់គ្រប់គ្រងវិជ្ជាស្ថានអប់រំ